NSW STATEWIDE INFANT SCREENING – HEARING (SWISH) PROGRAM

# Why does my baby need a diagnostic assessment?



## ហេតុអ្វីបានជាកូនរបស់ខ្ញុំត្រូវការការវាយតម្លៃមួយជាចាំបាច់ដើម្បីវិនិច្ឆ័យសោតវិញ្ញាណ?

បើសិនជាកូនលោកអ្នកមិនបានង្ហាញនូវលទ្ធផលជាក់ច្បាស់ណាមួយ ទៅនឹងការពិនិត្យមើលសោតវិញ្ញាណលើកដំបូងទាំង២ដងនោះទេ កូនលោកអ្នកនឹងត្រូវការការវាយតម្លៃមួយជាចាំបាច់ដើម្បីវិនិច្ឆ័យសោតវិញ្ញាណ។ ការវាយតម្លៃនេះ អាចបណ្តាលមកពីមូលហេតុមួយចំនួន។

មូលហេតុនោះអាចបណ្តាលមកពី:

- កូនលោកអ្នកអាចប្រហែលជាបានមានការភ័យភ្ញាក់ផ្អើល នៅគ្រាដែលគេឆែកពិនិត្យ។
- មានទឹកឬក៏អ្វីមួយរាំងស្ទះជាបណ្តោះអាសន្ននៅក្នុងត្រចៀកកូនលោកអ្នកក្រោយពីប្រសូតរួច។
- កូនលោកអ្នកអាចបាត់បង់នូវសោតវិញ្ញាណខ្លះៗ (ត្រចៀកធ្ងន់)។

ជាការសំខាន់ណាស់ដែលលោកអ្នកស្វែងយល់ឲ្យបានឆាប់ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ថាតើកូនលោកអ្នកស្តាប់ឮបានប៉ុណ្ណា ដើម្បីឲ្យលោកអ្នកនិងកូនលោកអ្នកអាចទទួលនូវឱវាទនិងជំនួយត្រឹមត្រូវស្តីអំពីការបាត់បង់សោតវិញ្ញាណនេះ។

### តើនឹងមានអ្វីកើតឡើងនៅគ្រាធ្វើការវាយតម្លៃនេះ?

គោលបំណងនៃការវាយតម្លៃដើម្បីវិនិច្ឆ័យសោតវិញ្ញាណនេះ គឺដើម្បីឲ្យមានការយល់ដឹងពេញលេញថែមទៀតអំពីសោតវិញ្ញាណរបស់កូនលោកអ្នក។
ការវាយតម្លៃនេះនឹងរួមបញ្ចូលនូវការធ្វើតេស្តមួយចំនួន។
ការធ្វើតេស្តទាំងនេះនឹងផ្តល់នូវព័ត៌មានពិស្តារអំពីរបៀបដែលកូនលោកអ្នកស្តាប់ឮ។

គ្រូពេទ្យសោតវិញ្ញាណ ដែលជាអ្នកឯកទេសម្នាក់ខាងការធ្វើតេស្តសោតវិញ្ញាណ នឹងធ្វើតេស្តទាំងនោះ។ តេស្តទាំងនោះនឹងមិនធ្វើឲ្យមានការឈឺចាប់ចំពោះកូនលោកអ្នកឡើយ។

### តើខ្ញុំត្រៀមរៀបចំកូនខ្ញុំរបៀបណាដែរ ដើម្បីការវាយតម្លៃនេះ?

ជាការប្រសើរបំផុត បើសិនជាកូនលោកអ្នកគេងលក់ នៅក្នុងអំឡុងពេលធ្វើតេស្តទាំងនោះ។ ជាការល្អម៉្យាងដែរ បើសិនជាលោកអ្នកអាចពន្យារពេលបំបៅកូន និងពេលដែលកូនគេង នៅថ្ងៃធ្វើតេស្តនោះ រហូតទៅដល់ពេលដែលលោកអ្នកយកកូនទៅដល់នាយកដ្ឋានពិនិត្យមើលសោតវិញ្ញាណ។ សូមអញ្ជើញទៅទីនោះ ឲ្យបានមុនកាលកំណត់បន្តិច ដើម្បីផ្តល់ពេលឲ្យលោកអ្នកបំបៅកូន ហើយលួងសំរួលឲ្យកូនគេង។

បើសិនជាលោកអ្នកមានកូនដទៃទៀតនៅឯផ្ទះ សូមរៀបចំឲ្យមាននរណាមួយមើលថែទាំកូនទាំងនោះ ដើម្បីឲ្យលោកអ្នកអាចនៅជាមួយកូនតូចនេះ។

November 2002 SHPN (PHCC) 030088
Khmer

NSW HEALTH
Working as a Team

ដោយសារការវាយតម្លៃធ្វើវិនិច្ឆ័យសោតវិញ្ញាណមានរួមបញ្ចូលទាំងការធ្វើតេស្តថែមលើសពីពេលពិនិត្យមើលគ្រាដំបូងនោះ លោកអ្នកគួរតែត្រៀមទុកពេលមួយព្រឹក ឬក៏មួយរសៀល ដោយអាស្រ័យទៅលើពេលណាត់ជួបដែលកំណត់ធ្វើឡើងនោះ។

**តើការធ្វើតេស្តវិនិច្ឆ័យសោតវិញ្ញាណនេះ ធ្វើឡើងដោយរបៀបណាខ្លះ?**
ការធ្វើតេស្តវិនិច្ឆ័យសោតវិញ្ញាណនេះមានឈ្មោះថា ការធ្វើតេស្តឲ្យមានការឆ្លើយតបពីខួរក្បាលពាក់ព័ន្ធនឹងការស្តាប់ (Auditory Brainstem Response [ABR]) ។ គេនឹងដាក់ប្រដាប់ចាប់វិញ្ញាណស្រដៀងគ្នាទៅនឹងប្រដាប់ចាប់វិញ្ញាណដែលគេប្រើនៅគ្រាពិនិត្យមើលសោតវិញ្ញាណគ្រាដំបូងនោះ ទៅលើក្បាលកូនរបស់លោកអ្នក។ គេនឹងលេងសូរសម្លេងឲ្យកូនលោកអ្នកស្តាប់តាមរយៈការបញ្ចូលតាមឧបករណ៍សំរាប់ពាក់ស្តាប់ ឬក៏ប្រដាប់ស៊កត្រចៀក។
ការឆ្លើយតបរបស់កូនលោកអ្នកទៅនឹងសូរសម្លេងនេះ នឹងត្រូវគេថតតាមរយៈប្រព័ន្ធអេឡិចត្រូនិច ហើយប្រព័ន្ធនេះ នឹងធ្វើការសំរេចអំពីកំរិតនៃសម្លេងស្រាលបំផុត ដែលកូនលោកអាចស្តាប់ឮ។

**តើនឹងមានអ្វីកើតឡើងក្រោយពីការធ្វើតេស្តទាំងនោះរួចនោះ?**
គ្រូពេទ្យសោតវិញ្ញាណនឹងមានលទ្ធភាពជំរាបលោកអ្នកអំពីលទ្ធផលទាំងឡាយ ហើយពន្យល់អំពីអត្ថន័យនៃលទ្ធផលទាំងនោះ ជាទូទៅគឺធ្វើឡើងនៅក្នុងថ្ងៃជាមួយគ្នានោះ។ បើសិនជាការធ្វើតេស្តទាំងនេះរកឃើញថាកូនលោកអ្នកបាត់បង់នូវសោតវិញ្ញាណអ្វីមួយនោះ គេនឹងបញ្ជូនលោកអ្នកទៅកាន់សេវាកម្មឯកទេសសមរម្យត្រឹមត្រូវ។ គេនឹងបញ្ជូនរបាយការណ៍មួយទៅកាន់សេវាកម្មនោះ ហើយលោកអ្នកនិងវេជ្ជបណ្ឌិតរបស់លោកអ្នកនឹងបានទទួលសំណៅរបាយការណ៍មួយច្បាប់ផងដែរ ដោយមានការយល់ព្រមពីលោកអ្នក។ គ្រូពេទ្យសោតវិញ្ញាណ និងអ្នកសំរបសំរួលសេវាកម្មសុខភាពក្នុងតំបន់ នឹងជួយលោកអ្នកព្រមទាំងកូនលោកអ្នកឲ្យបានទទួលសេវាកម្មនិងជំនួយដែលលោកអ្នកអាចត្រូវការ។

បើសិនជាគេរកឃើញថាកូនលោកអ្នកមានសោតវិញ្ញាណធម្មតា ប៉ុន្តែដំណាក់កាលក្រោយមកទៀត ស្រាប់តែលោកអ្នកមានការបារម្ភអំពីការលូតលាស់នៃសោតវិញ្ញាណ ការនិយាយ ឬក៏ភាសារបស់កូនលោកអ្នកនោះ សូមរៀបចំឲ្យមានការធ្វើតេស្តសោតវិញ្ញាណរបស់កូនលោកអ្នកម្តងទៀត។
ការធ្វើតេស្តពិនិត្យមើលសោតវិញ្ញាណអាចធ្វើឡើងគ្រប់វ័យទាំងអស់។

ការណាត់ជួបសំរាប់កូនលោកអ្នក គឺ:

---

**ចំពោះព័ត៌មានបន្ថែម សូមទាក់ទង:**

SWISH Information Line
Freecall 1800 551 175
NSW Department of Health
Tel. (02) 9391 9000
Fax. (02) 9391 9101
NSW HealthWeb site: www.health.nsw.gov.au

© NSW Health Department 2002

November 2002 SHPN (PHCC) 030088
Khmer

NSW HEALTH
Working as a Team